ASIAN AMERICANS ADVANCING JUSTICE
ASIAN LAW CAUCUS

# របៀបបោះឆ្នោតសម្រាប់ការបោះឆ្នោតសកលឆ្នាំ2020 ក្នុងរដ្ឋ California

## ធ្វើការរៀបចំ

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកគួរចូលទៅកាន់គេហទំព័រ voterstatus.sos.ca.gov ដើម្បីធ្វើឱ្យប្រាកដថារាល់ព័ត៌មានរបស់អ្នកទាំងអស់គឺត្រឹមត្រូវ ។ ពិនិត្យមើលអាសយដ្ឋាន អាសយដ្ឋានអ៊ីម៉ែល និងការបង្ហាញរបស់អ្នក ប្រសិនបើអ្នកចង់ទទួលបានឯកសារបកប្រែសម្រាប់ការបោះឆ្នោត។.

ប្រសិនបើអ្នកមិនទាន់ត្រូវបានចុះឈ្មោះបោះឆ្នោតទេ អ្នកអាចចុះឈ្មោះបោះឆ្នោតតាមអនឡាញនៅគេហទំព័រ registertovote.ca.gov ឬទៅយកពាក្យសុំចុះឈ្មោះបោះឆ្នោតនៅ DMV ប៉ុស្តិ៍ប្រៃសណីយ៍ ឬការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នក។ អ្នកក៏អាចចុះឈ្មោះបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ប្រសិនបើអ្នកខកខានហួសពេលកំណត់។

## បោះឆ្នោតពីលំនៅឋាន

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតត្រឹមថ្ងៃទី19 ខែតុលា អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍។ បំពេញសន្លឹកឆ្នោតរបស់អ្នក ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើវា។ អ្នកអាចផ្ញើសន្លឹកឆ្នោតមកវិញតាមប្រៃសណីយ៍។ វាមិនទាមទារត្រាប្រៃសណីយ៍ទេ! ត្រូវប្រាកដថាវាមានសញ្ញាសម្គាល់**ប្រៃសណីយ៍**មុនពេលចុងបញ្ចប់នៃថ្ងៃទី3 ខែវិច្ឆិកា។ អ្នកអាច**ផ្ញើវា**ទៅការិយាល័យបោះឆ្នោតនៃខោនធីរបស់អ្នក ឬមណ្ឌលឬកន្លែងបោះឆ្នោតណាមួយ។ ខោនធីភាគច្រើនក៏មានប្រអប់សុវត្ថិភាពសម្រាប់ដាក់សន្លឹកឆ្នោត ដែលមានចាប់ពីដើមខែតុលាមក។

## ការបោះឆ្នោតដោយផ្ទាល់

បោះឆ្នោតគឺនៅ**ថ្ងៃអង្គារ ទី** 3 **ខែវិច្ឆិកា ឆ្នាំ** 2020។ មណ្ឌលបោះឆ្នោតនឹងចាប់ផ្តើមបើកពីម៉ោង 7 **ព្រឹក ដល់ម៉ោង** 8 **ល្ងាច។** អ្នកអាចស្វែងរកមើលទីតាំងបោះឆ្នោតនៅទីនេះ៖ sos.ca.gov/elections/polling-place ខោនធីភាគច្រើនក៏នឹងផ្តល់ការបោះឆ្នោតដោយផ្ទាល់ចាប់ផ្តើមនៅថ្ងៃសៅរ៍ ខែ31 ខែតុលា ឆ្នាំ2020 ហើយមានការបោះឆ្នោតដោយផ្ទាល់ខ្លះចាប់ផ្តើមមុនកាលបរិច្ឆេទនេះ។ ពិនិត្យជាមួយការិយាល័យបោះឆ្នោតមូលដ្ឋានរបស់អ្នក។ អ្នកអាចរកមើលទីតាំងនិងប្រអប់ដាក់សន្លឹកឆ្នោតជាមុននៅទីនេះ៖ caearlyvoting.sos.ca.gov ដើម្បីឱ្យដំណើរការងាយស្រួល ចូរព្យាយាមយកសន្លឹកឆ្នោតរបស់អ្នកមកជាមួយវិញ ប្រសិនបើអ្នកបានទទួលសន្លឹកឆ្នោតមួយតាមប្រៃសណីយ៍រួចហើយ។







55 Columbus Avenue, San Francisco, CA 94111 | T (415) 896-1701 | www.advancingjustice-alc.org